# ព្រះវិហារវត្តអំពិល

វត្តអំពិល ឬហៅថាវត្តអំពិលពោធិប្រាក់ ស្ថិតនៅក្នុងភូមិសាស្ត្រឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ជាប់ស្រុកក្រឡាញ់ ខេត្តសៀមរាប។ វត្តនេះកសាងនៅប្របដងស្ទឹងក្រឡាញ់ ពោលគឺនៅខាងជើងវត្តទន្ទាប់ចម្ងាយប្រហែល៥គីឡូម៉ែត្រ។[១] យោងតាមឯកសារឱ្យដឹងថា ព្រះវិហារវត្តនេះកសាងនៅដើមសតវត្សទី២០ ហើយគំនូរក្នុងព្រះវិហារគូរក្នុងឆ្នាំ១៩៤១។[២] ក្រោយឆ្លងកាត់សង្គ្រាម និងការបំផ្លិចបំផ្លាញ ទើបចូលមកដល់ដើមសតវត្សទី២១ ព្រះវិហារវត្តនេះបានជួសជុលរចនាសម្ព័ន្ធ និងគ្រឿងលម្អផ្នែកដំបូល ដោយរក្សាលំនាំស្ថាបត្យកម្មដើម ព្រមទាំងជួសជុលកែលម្អ កសាងបន្ថែមខឿនជុំវិញព្រះវិហារ និងកសាងបល្ល័ង្កព្រះដីវ៍ថ្មី (រូបលេខ១)។



រូបលេខ១ ព្រះវិហារវត្តអំពិល មើលពីជ្រុងពាយ័ព្យ

---

[១] សូមអាន "វិហារវត្តទន្ទាប់" ផ្សាយលើគេហទំព័រ AMS Khmer Civilization ថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ លើតំណ https://ams.com.kh/khmercivilization/detail/17698

[២] *Danielle & Dominique-Pierre Guéret 2017: 146-147*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*ព្រះវិហារវត្តអំពិល ជាទម្រង់វិហារជហ្វាបួន ដែលលក្ខណៈសំណង់ទូទៅស្រដៀងនឹងព្រះវិហារបុរាណមួយចំនួននៅក្នុងខេត្តបាត់ដំបង និងសៀមរាប។ សម្ភារៈ សំណង់ជាទូទៅប្រើជាគ្រឿងបង្គុំនៅផ្នែកដំបូល និងសសរជាឈើ ហើយផ្នែកជញ្ជាំងជុំវិញជាឥដ្ឋបូកកំបោរបាយអ។ តាមរយៈរូបថតសាលាបារាំងថតឆ្នាំ១៩២៩ (EFEO_CAM15633) បង្ហាញឱ្យឃើញថាព្រះវិហារនេះកសាងលើកូនទួលមួយ ព័ទ្ធដោយចេតិយតូចៗជុំវិញ។ ដំបូលប្រក់ក្បឿងស្រកាលេញ បំពាក់ជហ្វា២ នៅចុងមេដំបូលខាងកើត និងជហ្វា២ ទៀតនៅចុងមេដំបូលខាងលិច ដោយរចនាចុងដំបូល និងជហ្វាទាំងសងខាងឱ្យខ្ពស់ស្រឡះឡើងៗ រីឯហោជាងទាំងសងខាងនៃព្រះវិហារវត្តនេះ គេរចនាដោយសសរទម្រពី កើតជាចន្លោះលំហទំនេរ ពុំមានលម្អដោយក្បាច់រចនាអ្វីដូចវិហារបុរាណវត្តសំពោងក្នុង ឬវត្តបាឡាត់ ឬវត្តកណ្ដឹងក្នុងខេត្តបាត់ដំបូងឡើយ។ ចំណែកផ្ទៃដំបូលចំហៀងរាងជ្រាលចុះ៣ថ្នាក់ ទ្រដោយសសរឈរចំនួន១២ដើមនៅខាងក្នុង និងសសរឈើចំនួន៣០ដើម តាមបៀងបាំងសាច។ លក្ខណៈរចនាសម្ព័ន្ធទូទៅទាំងឡាយនេះ គេឃើញរក្សាបានស្ទើរទាំងស្រុង រហូតមកដល់សព្វថ្ងៃ (រូបលេខ២-៣)។*



***រូបលេខ២ ព្រះវិហារវត្តអំពិល មើលពីជ្រុងនិរតី (រូបថត៖ EFEO, ឆ្នាំ១៩២៨)***



***រូបលេខ៣ ព្រះវិហារវត្តអំពិលបច្ចុប្បន្ន មើលពីជ្រុងនិរតី***

*ប៉ុន្តែទោះបីយ៉ាងណាក្ដី ក្រោយមានការបំផ្លិចបំផ្លាញក្នុងសម័យសង្គ្រាម នៅក្នុងរវាងឆ្នាំ២០០០ ព្រះវិហារវត្តអំពិលនេះ បានចាប់ផ្ដើមជួសជុលកែលម្អរចនាសម្ព័ន្ធជាច្រើនកន្លែងៗ នៅផ្នែកដំបូល គេបានបំពាក់នាគដងក្ដារថ្មី ជាក្បាច់ចាក់ពុម្ពស៊ីម៉ងត៍នៅតាមចែងដំបូលនីមួយៗ និងបានប្ដូរសសរទ្រហោជាងពីឈើទៅជាបេតុង ព្រមទាំងលាបពណ៌ថ្មី*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ផងដែរ។ លើសពីនេះគេថែមទាំងបានរៀបចំបន្ថែមបង្កាន់ដៃព័ទ្ធជុំវិញ ដោយមានជណ្តើរឡើងចុះនៅផ្នែកខាងមុខ២ និងខាងក្រោយពីរ។ ទន្ទឹមនឹងនេះ ចំពោះការ៉ូកម្រាលទាំងក្នុង និងខាងក្រៅក៏បានប្តូរមកប្រើប្រាស់ការ៉ូសម័យថ្មីផងដែរ (រូបលេខ២៨-៥)។



រូបលេខ២៨ ព្រះវិហារវត្តអំពិលមើលពីចំហៀង



រូបលេខ២៥ របៀងបាំងសាចវិហារ

ដោយឡែក ចំពោះហោជាងទាំងពីរនៃព្រះវិហារវត្តអំពិល ជាប្រភេទហោជាងឈើរចនាដោយក្បាច់ភ្ញីទេស ព្រមទាំងមានជុំកញ្ចក់លម្អផង។ ផ្ទៃហោជាងខាងកើត គេរចនាជារូបព្រះសក្យមុនីចេតិយ(?) មួយធំនៅចំកណ្តាល និងដងទង់ពីរអមសខាងខាង ព្រមទាំងរូបទេព្តាអង្គុយប្រណម្យនៅផ្នែកខាងក្រោម ព័ទ្ធលម្អដោយក្បាច់ភ្ញីទេស(រូបលេខ២៦)។ ប្រធានបទលើផ្ទៃហោជាងនេះ ហាក់ស្រដៀងនឹងហោជាងផ្នែកខាងកើតនៃវិហារបុរាណវត្តល្អក់ ក្នុងខេត្តសៀមរាបដែរ។[1] ចំណែកឯនៅលើផ្ទៃហោជាងខាងលិច គេសង្កេតឃើញថាក្បាច់លម្អជាទូទៅពុកផុយជ្រុះធ្លាក់បាត់ដោយផ្នែក។ យ៉ាងណាក្តី នៅលើហោជាងនេះ គេរចនាជារូបទេពគង់លើគ្រុឌ(ព្រះវិស្ណុ?) ដោយនៅក្នុងព្រះហស្តទាំងសងខាងមានកាន់កេតនភណ្ឌផង (រូបលេខ២៧)។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់ ហោជាងទាំងពីរនេះគេប្រើបន្ទះក្តារផ្តេក ហើយយកក្បាច់ ព្រមទាំងកញ្ចក់លម្អបិទភ្ជាប់ពីលើ។

---

[1] សូមអាន "ព្រះវិហារវត្តល្អក់" ផ្សាយលើគេហទំព័រ *AMS Khmer Civilization* ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ លើតំណ https://ams.com.kh/khmercivilization/detail/22519

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត



*រូបលេខ២៦ ហោជាងខាងកើត*



*រូបលេខ២៧ ហោជាងខាងលិច*

ចំពោះជញ្ជាំងព្រះវិហារផ្នែកខាងក្រៅ ជាទូទៅមានផ្ទៃលាតគ្មានក្បាច់លម្អ ឬគំនូរអ្វីឡើយ ដោយនៅផ្នែកចំហៀងមានបង្អួចម្ខាង៥។ រីឯនៅលើជញ្ជាំងផ្នែកខាងមុខ មានទ្វារពីរ និងជញ្ជាំងខាងក្រោយមានទ្វារពីរ។ ទន្ទឹមនឹងនេះ នៅលើជញ្ជាំងខាងកើតគេឃើញមានផ្តែរប្រាសាទមួយត្រូវបានគេយករៀបភ្ជាប់នឹងផ្ទៃជញ្ជាំងផ្នែកកណ្តាលផង (រូបលេខ២៨)។ ប៉ុន្តែដោយឡែក នៅលើសន្ទឹកទ្វារ និងបង្អួចនីមួយៗនៃព្រះវិហារនេះ គេថែមទាំងបានរចនាលម្អដោយក្បាច់ផ្កាភ្ញី រួមទាំងតួអង្គហនុមាន ដែលគេស្គាល់ថាជាតួអង្គសំខាន់ៗមួយចំនួនក្នុងរឿងរាមកេរ្តិ៍ (រូបលេខ២៩-១១)។



*រូបលេខ២៨ ផ្តែរប្រាសាទដែលយកមករៀបភ្ជាប់ជញ្ជាំងខាងកើតនៃព្រះវិហារវត្តអំពិល*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩ ក្បាច់លម្អលើបង្អួចវិហារវត្តអំពិលថតឆ្នាំ១៩២៩ (រូបថត៖ EFEO)





រូបលេខ១០-១១ ចម្លាក់រូបហនុមាន និងក្បាច់លម្អលើទ្វារ និងបង្អួចខ្លះ នៃវិហារវត្តអំពិលសព្វថ្ងៃ

នៅផ្នែកខាងក្នុងព្រះវិហារ មានសសរឈើ៨ ជ្រុងពីរជួរអមសាងខាងល្វែងគ្រឹះ។ សសរនីមួយៗ ជាសសរលាត ពុំមានក្បាច់ ឬគំនូរលម្អអ្វីឡើយ។ រីឯផ្នែកខាងលើ គឺជាគ្រឿងបង្គុំឈើទាំងអស់ ហើយពិតានព្រះវិហារនេះក៏ជាពិតានឈើ ដែលគេដឹងថាទើបនឹងរៀបចំជួសជុលកែលម្អថ្មី (រូបលេខ១២-១៣)។ ចំពោះបល្ល័ង្កព្រះដីរ៍ នៃព្រះវិហារវត្តនេះ គេក៏ដឹងដែរថាជាបល្ល័ង្កដែលទើបនឹងរៀបចំកសាងថ្មីនៅក្នុងពុទ្ធសករាជ២៥២៩ (ឆ្នាំ២០០៥) ដោយដាក់តម្កល់ព្រះពុទ្ធបដិមាព្រះដីរ៍ធំសាងអំពីសីម៉ង់ត៍ អមដោយព្រះពុទ្ធបដិមាក្នុងកាយវិការផ្ចាញ់មារបីព្រះអង្គ ជាព្រះបដិមាសាងអំពីស៊ីម៉ង់ត៍។ ដូច្នេះគេពុំដឹងថា ព្រះបដិមាព្រះដីរ៍ដើមនៃព្រះវិហារនេះមានលក្ខណៈដូចម្ដេចឡើយ៕





រូបលេខ១២-១៣ គ្រឿងបង្គុំឈើផ្នែកខាងលើ និងពិតានព្រះវិហារដែលរៀបចំថ្មី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត